

International Labour Office

# ILO

# សូចនាករស្តីពីពលកម្ម ដោយបង្ខំរបស់អង្គការ អន្តរជាតិខាងការងារ

កម្មវិធីសកម្មភាពពិសេសដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មដោយបង្ខំ

# ការណែនាំឲ្យដឹងពីសូចនាករ

កូនសៀវភៅព័ត៌មាននេះណែនាំបង្ហាញអំពីសូចនាករស្ដីពីពលកម្មដោយ
បង្ខំរបស់អង្គការ ILO ។
សូចនាករទាំងនេះមានបំណងជួយមន្ត្រីអនុវត្តច្បាប់ប្រឆាំងបទល្មើស
នៅ  "ជួរមុខ " អ្នកធ្វើអធិការកិច្ចការងារ មន្ត្រីសហជីព
បុគ្គលិកអង្គការ  NGO និងអ្នកពាក់ព័ន្ធឯទៀតដើម្បី
កំណត់អត្តសញ្ញាណជនដែលត្រូវជាប់ផុងខ្លួនក្នុងស្ថានភាពពលកម្មដោ
យបង្ខំ ដែលអាចត្រូវការ ជំនួយជាបន្ទាន់។
សូចនាករទាំងអស់តំណាងសញ្ញាច្បាស់លាស់បំផុត ឬជា "គម្រុយ " ដែល
ចង្អុលបង្ហាញពីករណីពលកម្មដោយបង្ខំដែលកើតឡើងជាយថាហេតុ។

សូចនាករទាំងអស់ត្រូវបានបង្កើតចេញពីបទពិសោធន៍ជាក់ស្ដែង
និងបទពិសោធន៍ជា ទ្រឹស្ដីនៃកម្ម វិធីសកម្មភាពពិសេសរបស់អង្គការ
ILO ដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មដោយ បង្ខំ (SAP-FL) ។
វាផ្អែកលើនិយមន័យអំពីពលកម្មដោយបង្ខំដែលចែងក្នុងអនុសញ្ញាស្ដីពី
ពលកម្មដោយបង្ខំរបស់អង្គការ  ILO នៅឆ្នាំ១៩៣០ (លេខ២៩)
ដែលចែងថា៖  "រាល់ ការងារ ឬសេវាកម្មដែលទទួលពីជនណាម្នាក់
ដែលត្រូវបានគំរាមកំហែងដាក់ទណ្ឌកម្ម
ហើយដែលជននោះមិនស្ម័គ្រចិត្តធ្វើដោយខ្លួនគាត់ " ។

កូនសៀវភៅព័ត៌មាននេះបង្ហាញសូចនាករចំនួនដប់មួយ
ដោយផ្តល់ឧទាហរណ៍ជីវិតជាក់
ស្តែងដើម្បីបង្ហាញដោយមានការពន្យល់ត្រួសៗពីន័យរបស់សូចនាករ។
សូចនាករទាំងនេះនឹង
ជួយអ្នកឱ្យយល់ពីវិធីដែលពលកម្មដោយបង្ខំកើតឡើង
និងពីវិធីដែលវាប៉ះពាល់ដល់ ជនរងគ្រោះ។

# សូចនាករទាំងនេះគឺ:

- ការរំលោភបំពានលើភាពងាយរងគ្រោះ
- ការបោកបញ្ឆោត
- ការដាក់កំហិតការដើរហើរ
- ការដាក់ឱ្យនៅឯកោ
- អំពើហឹង្សាលើផ្លូវកាយ និងផ្លូវភេទ
- ការសម្លុត និងការគំរាមកំហែង
- ការដកហូតឯកសារអត្តសញ្ញាណ
- ការកាត់ប្រាក់ខែទុក
- បំណុលទាសភាព
- ល័ក្ខខ័ណ្ឌការងារ និងរស់នៅប្រកបដោយការរំលោភបំពាន
- ការធ្វើការបន្ថែមម៉ោងហួសហេតុ

វត្តមាននៃសូចនាករតែមួយក្នុងស្ថានភាពមួយដែលកើតឡើងក្នុងករណីខ្លះអាចមានន័យថា ពលកម្មដោយបង្ខំបានកើតឡើង។ ប៉ុន្តែក្នុងករណីឯទៀតអ្នកត្រូវពិនិត្យមើលសូចនាករជាច្រើនរួមគ្នាទើបវាបង្ហាញថា មានករណីពលកម្មដោយបង្ខំ។ ជាទូទៅសូចនាករទាំងដប់មួយនេះគ្របដណ្តប់លើធាតុផ្សំសំខាន់ៗនៃស្ថានភាពពលកម្មដោយបង្ខំដូច្នេះវាផ្តល់ជាមូលដ្ឋានដើម្បី ពិចារណាថា តើពលករជាជនរងគ្រោះដោយបទល្មើសនេះឬអត់។

គោលការណ៍ណែនាំច្រើនទៀតពីវិធីប្រើសូចនាករទាំងអស់មានចែងក្នុងឧបករណ៍ ការសិក្សាតាមអេឡិចត្រូនិចនៃអង្គការ ILO ស្តីពីការកំណត់អត្តសញ្ញាណ និងការស៊ើបអង្កេតករណីពលកម្មដោយបង្ខំ។



# ការរំលោភបំពានលើភាពងាយរងគ្រោះ

“អ្នកបំរើជាជនជាតិចិនម្នាក់ដែលធ្វើការ៣៦៥ថ្ងៃក្នុងមួយឆ្នាំមិនចេះនិយាយភាសាបារាំងមួយពាក្យឡើយ លើកលែងតែពាក្យ “អរុណសួស្តី ” និង “រាត្រីសួស្តី ” ។ នាងត្រូវបានគេដាក់ឱ្យនៅក្នុងស្ថានភាពពឹងផ្អែកលើគេពីព្រោះតែភាសា ធ្វើការងារគ្មានឈប់ឈរ និងដាក់ឱ្យនៅ ឯកោ។ ស្ត្រីអ្នកបំរើនោះជាទាសករយ៉ាងពិតប្រាកដ ” ។

អ្នកធ្វើអធិការកិច្ចការងារម្នាក់នៅប្រទេសបារាំង

---

ជនណាក៏អាចជាជនរងគ្រោះនៃពលកម្មដោយបង្ខំដែរ។ ប៉ុន្តែ មនុស្សដែលខ្វះចំណេះដឹងភាសា ឬច្បាប់ក្នុងមូលដ្ឋាន មានជំរើសធ្វើការចិញ្ចឹមជីវិតតិចតួច មនុស្សដែលជាក្រុមជនជាតិភាគតិច ឬក្រុមសាសនាភាគតិច មនុស្សមានពិការភាព ឬមានលក្ខណៈឯទៀតដែលដាក់ពួកគេឱ្យឆ្ងាយពីប្រជាជន ភាគច្រើនមានភាពងាយរងគ្រោះជាពិសេសចំពោះការរំលោភបំពាន ហើយជា រឿយៗបំផុតស្ថិតក្នុងពលកម្មដោយបង្ខំ។

កត្តាដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ជាឧទាហរណ៍គឺកង្វះខាតជំរើសផ្សេងសំរាប់ការចិញ្ចឹមជីវិតមិននាំឱ្យមនុស្សម្នាក់ធ្លាក់ខ្លួនក្នុងពលកម្មដោយបង្ខំទេ។ ជាស្ថានភាពពលកម្មដោយ បង្ខំគឺ នៅពេលដែលនិយោជកម្នាក់កេងចំណេញលើស្ថានភាពងាយរងគ្រោះរបស់កម្មករម្នាក់ ជាឧទាហរណ៍ គឺការដាក់ឱ្យធ្វើការច្រើនម៉ោងហួសហេតុ ឬកាត់ប្រាក់ឈ្នួលទុកនោះហើយ ជាស្ថានភាពពលកម្មដោយបង្ខំអាចកើតឡើង។ ពលកម្មដោយបង្ខំក៏ទំនងជាកើតឡើងក្នុងករណីពឹងផ្អែកទាំងស្រុងលើនិយោជក ដូចជានៅពេលដែលកម្មករពឹងផ្អែកលើនិយោជក មិនត្រឹមតែសំរាប់ការងាររបស់ខ្លួនទេ ប៉ុន្តែលើផ្ទះសំបែង អាហារ ឬការងារសំរាប់ញាត្តិ មិត្តរបស់គាត់។



# ការបោកបញ្ឆោត

“ម្ដាយខ្ញុំបានប្រាប់ខ្ញុំថាប្អូនស្រីគាត់មានគំរោងមកយកខ្ញុំទៅរស់នៅជាមួយគាត់។ គឺជាម្ដាយ មីងខ្ញុំ ដែលបានសន្យាថាបង់ចំណាយលើការសិក្សារបស់ខ្ញុំ ប៉ុន្តែមិនធ្វើតាមការសន្យារបស់គាត់ឡើយ។ ផ្ទុយទៅវិញ គាត់បានបញ្ជូនខ្ញុំទៅធ្វើជាអ្នកបំរើម្នាក់ ”។

នារីវ័យក្មេងជាតិហ្សំបីម្នាក់

---

ការបោកបញ្ឆោតពាក់ព័ន្ធនឹងការអាក់ខានមិនបានផ្តល់អ្វីដែលបានសន្យាជាលាយល័ក្ខអក្សរ ឬ ដោយផ្ទាល់មាត់ដល់កម្មករ។ ជារឿយៗជនរងគ្រោះដោយពលកម្មដោយបង្ខំបានត្រូវការគេ ជ្រើសរើសដោយមានការសន្យាថាផ្តល់ការងារសមស្រប មានប្រាក់ខែខ្ពស់។ ប៉ុន្តែនៅពេលចាប់ ផ្តើមធ្វើការ ល័ក្ខខ័ណ្ឌការងារមិនដូចការសន្យាទេ ហើយកម្មករយល់ឃើញថាខ្លួនធ្លាក់ក្នុងស្ថាន ភាពរំលោភបំពាន ដោយពុំមានលទ្ធភាពភៀសខ្លួនបានឡើយ។ ក្នុងករណីទាំងនេះ កម្មករមិនមានសេរីភាព និងមិនអាចមានការយល់ព្រមច្បាស់លាស់ទេ។ បើពួកគេបានដឹងបញ្ហានេះ ជាមុន ពួកគេប្រាកដជាមិនទទួលការងារនេះឡើយ។

ការជ្រើសរើសដោយបោកបញ្ឆោតអាចរួមមានការសន្យាក្លែងក្លាយអំពីប្រាក់ឈ្នួល និង ល័ក្ខខ័ណ្ឌការងារ ប្រភេទការងារ ល័ក្ខខ័ណ្ឌរស់នៅ និងផ្ទះសំបែង ការទទួលបានស្ថានភាព ទេសន្តរប្រវេសន៏ទៀងទាត់ ទីតាំងការងារ ឬអត្តសញ្ញាណនៃនិយោជក។ កុមារក៏អាចត្រូវបានគេជ្រើសរើសតាមរយៈ ការសន្យាក្លែងក្លាយចំពោះពួកគេ ឬឪពុកម្តាយអំពីការសិក្សា ឬការទៅសួរសុខទុក្ខជាញឹកញយដោយពួកគេ ឬដោយឪពុកម្តាយពួកគេ។



# ការដាក់កំហិតលើការដើរហើរ

" មានចំរឹងដែកនៅលើបង្អួច និងទ្វារដែកដូចជាពន្ធនាគារមួយ។ មិនអាចមានលទ្ធភាព ភៀសខ្លួន បានទេទោះជាគិតបំរុងភៀសខ្លួនក៏ដោយ។ អស់រយៈពេលពីរខែ ពួកគេបាននាំខ្ញុំ ទៅឲ្យអតិថិជន រួច ហើយនាំខ្ញុំមកវិញក្រោមការការពារយ៉ាងតឹងតែង"។

នារីអាយុ១៦ឆ្នាំម្នាក់មកពីកាហ្សាក់ស្ថង់ត្រូវបានគេជួញដូរឲ្យធ្វើជាពេស្យានៅរុស្ស៊ី

---

ជនរងគ្រោះដោយពលកម្មដោយបង្ខំអាចត្រូវគេចាក់សោរបង្ខាំង និងការពារដើម្បីកុំឲ្យ ពួកគេភៀសខ្លួនបាននៅពេលធ្វើការ ឬនៅពេលធ្វើដំណើរ។

ប្រសិនបើកម្មករមិនមានសេរីភាពដើម្បីចូល និងចាកចេញពីកន្លែងធ្វើការដោយសារមាន ការដាក់កំហិតមួយចំនួនដែលត្រូវបានចាត់ទុកថាមិនសមហេតុផល ទង្វើនេះបង្ហាញជា សូចនាករយ៉ាងច្បាស់លាស់មួយថាជាពលកម្មដោយបង្ខំ។ ការដាក់កំហិតតាមផ្លូវច្បាប់អាចរួម មានការដាក់កំហិតទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាព និងសន្តិសុខរបស់កម្មករ ក្នុងទីតាំងការងារប្រកបដោយគ្រោះថ្នាក់ ឬតំរូវការឲ្យសុំការអនុញ្ញាត្តិពីមេការដើម្បីការ ពិនិត្យសុខភាព។

ជនរងគ្រោះដោយពលកម្មដោយបង្ខំអាចត្រូវបានគេត្រួតពិនិត្យគ្រប់ចលនានៅក្នុងកន្លែង ធ្វើការ តាមរយៈការប្រើម៉ាស៊ីនថតស៊ើបការណ៍ ឬអ្នកការពារ ហើយនៅក្រៅកន្លែងធ្វើការ តាមរយៈភ្នាក់ងាររបស់និយោជកដែលអមដំណើរពួកគេនៅពេលចាកចេញពីកន្លែងធ្វើការ។



# ការដាក់ឱ្យនៅឯកោ

" ជំរុំនោះស្ថិតក្នុងតំបន់ដែលពិបាកទៅដល់។
ដើម្បីធ្វើដំណើរទៅទីប្រជុំជន អ្នកត្រូវមាន
ផែនការធ្វើដំណើរជាច្រើនថ្ងៃជាមុន។
ការធ្វើដំណើរអាចធ្វើបានតែតាមរយៈយន្តហោះធុនតូច
ឬកាណូតដែលអាចចំណាយពេលរហូតដល់២២ថ្ងៃ "។

ពលករជនជាតិភាគតិចម្នាក់ដែលបានភៀសខ្លួននៅប្រទេសប៉េរូ

---

ជារឿយៗ ជនរងគ្រោះដោយពលកម្មដោយបង្ខំត្រូវបានគេដាក់ឱ្យនៅឯកោក្នុងតំបន់ដាច់ ស្រយាល មិនឱ្យមានការទាក់ទងជាមួយពិភពខាងក្រៅឡើយ។

ពលករមិនស្គាល់ទីកន្លែងខ្លួនបានរស់នៅទេ ទីតាំងការងារអាចនៅឆ្ងាយពីលំនៅដ្ឋាន ហើយមិនមានមធ្យោបាយធ្វើដំណើរទេ។ ប៉ុន្តែស្រដៀងគ្នានោះដែរ ពលករអាចត្រូវបានគេដាក់ ឱ្យនៅឯកោក្នុងតំបន់ប្រជុំជនផងដែរដោយបង្ខាំងទុកក្នុងបន្ទប់ ឬដោយការដកហូតទូរស័ព្ទ ចល័ត ឬមធ្យោបាយទាក់ទងឯទៀតដើម្បីរារាំងមិនឱ្យពួកគេទាក់ទងគ្រួសារ ដើម្បីរកជំនួយ។

ភាពឯកោក៏មានទំនាក់ទំនងចំពោះទីតាំងអាជីវកម្មក្រៅប្រព័ន្ធ ដែលមិនបានចុះបញ្ជីការ ត្រឹមត្រូវ ដែលធ្វើឱ្យពិបាកដល់ស្ថាប័នអនុវត្តច្បាប់ ឬស្ថាប័នឯទៀតក្នុងការរកទីតាំងអាជីវកម្ម នោះដើម្បីពិនិត្យ ឃ្លាំមើលអ្វីដែលកំពុងកើតឡើងចំពោះពលករ។



# អំពើហឹង្សាលើផ្លូវកាយ និងផ្លូវភេទ

" ការរំលោភបំពានបានកើតឡើងភ្លាមបន្ទាប់ពីខ្ញុំបានទៅដល់ ហើយទង្វើនេះបានកើត ឡើងកាន់តែញឹកញាប់ និងកាន់តែហឹង្សា។ ជាធម្មតា ខ្ញុំត្រូវបានគេទះកំផ្លៀង វាយដោយរំពាត់ និងដាល់តប់ "។

ស្ត្រីកម្ពុជាម្នាក់អាយុ២២ឆ្នាំធ្វើការជាអ្នកបំរើតាមផ្ទះនៅម៉ាឡេស៊ី

ជនរងគ្រោះដោយពលកម្មដោយបង្ខំ សមាជិកគ្រួសាររបស់ពួកគេ និងមិត្តជិតស្និទ្ធអាច ទទួលរងអំពើហឹង្សាលើផ្លូវកាយ ឬផ្លូវភេទ។ អំពើហឹង្សាអាចរួមមានការបង្ខំពលករឱ្យប្រើ គ្រឿងញៀន ឬគ្រឿងស្រវឹងដើម្បីកាន់តែងាយត្រួតត្រាលើពួកគេ។ អំពើហឹង្សាក៏អាចត្រូវប្រើ ដើម្បីបង្ខំពលករឱ្យធ្វើការងារ ដែលមិនមានចែងក្នុងកិច្ចព្រមព្រៀងដូចជាការរួមភេទជាមួយ និយោជក ឬជាមួយសមាជិកគ្រួសារនិយោជក ឬឱ្យទទួលធ្វើការងារផ្ទះបន្ថែមច្រើនទៀត។ ការចាប់ពង្រត់ ឬការចាប់ខ្លួនដើម្បីជំរិតទារ ប្រាក់ជាទម្រង់អំពើហឹង្សាធ្ងន់ធ្ងរបំផុតដែលអាចត្រូវ បានគេប្រើដើម្បីឃុំឃាំងមនុស្ស ហើយបន្ទាប់មកបង្ខំឱ្យធ្វើការ។

អំពើហឹង្សាមិនអាចទទួលយកបានទេ ក្រោមវិធានការដាក់វិន័យនៅក្នុង កាលៈទេសៈ ណាមួយក៏ដោយ នេះគឺជាសូចនាការយ៉ាងច្បាស់លាស់មួយអំពីពលកម្មដោយបង្ខំ។



# ការសម្លុត និងការគំរាមកំហែង

" នៅពេលខ្ញុំប្រាប់ស្ត្រីដែលខ្ញុំធ្វើការឱ្យគាត់ថា ខ្ញុំចង់ចាកចេញ គាត់បានគំរាមកំហែងខ្ញុំ ហើយបាននិយាយថា ប្រសិនបើខ្ញុំមិនសងប្រាក់៦០០ដុល្លារទេនោះ គាត់នឹងទៅប្រាប់ប៉ូលីស ថាខ្ញុំគ្មានឯកសារទេ។ ខ្ញុំមិនអាចធ្វើអ្វីបានឡើយពីព្រោះខ្ញុំគ្មានឯកសារ ហើយខ្ញុំដឹងថាប៉ូលីស មិនអាចជួយខ្ញុំបានទេ "។

ពលករទេសន្តរប្រវេសន៍ជាតិអេត្យូពីម្នាក់អាយុ៣១ឆ្នាំនៅប្រទេសលីបង់

---

ជនរងគ្រោះដោយពលកម្មដោយបង្ខំអាចទទួលការឈឺចាប់ដោយសារការសម្លុត និងការ គំរាមកំហែងនៅពេលដែលពួកគេរអ៊ូរទាំអំពីល័ក្ខខ័ណ្ឌការងារ ឬចង់ឈប់ធ្វើការ។

បន្ថែមទៅលើការគំរាមកំហែងប្រើអំពើហឹង្សាលើរាងកាយ ការគំរាមកំហែងឯទៀតដែល ត្រូវបានប្រើលើពលកររួមមាន ការរាយការណ៍ដល់អាជ្ញាធរអន្តោប្រវេសន៍ ការកាត់ប្រាក់ឈ្នួល ឬការមិនឱ្យផ្ទះសំបែង ឬដីធ្លី ឬការបញ្ឈប់សមាជិកគ្រួសារ ឬការដាក់ល័ក្ខខ័ណ្ឌការងារកាន់ តែធ្ងន់ធ្ងរ ឬការដកហូត "សិទ្ធិ" ដូចជាសិទ្ធិចាកចេញពីកន្លែងធ្វើការជាដើម។ ការប្រមាថ មើលងាយឥតឈប់ឈរ និងការរារាំងពលករក៏បង្កើតជាទម្រង់បង្ខិតបង្ខំផ្លូវចិត្តផងដែរ។

ត្រូវធ្វើការវាយតម្លៃលើភាពទុកចិត្តបាន និងផលប៉ះពាល់នៃការគំរាមកំហែង តាំងពី ទស្សនៈវិស័យរបស់ពលករ ដោយយកពិចារណាលើជំនឿជាបុគ្គលរបស់គាត់ អាយុ សាវតា វប្បធម៌ ស្ថានភាពសង្គម និងសេដ្ឋកិច្ច។



# ការរក្សាទុកឯកសារអត្តសញ្ញាណ

"នៅពេលខ្ញុំឆ្លងកាត់ការិយាល័យអន្តោប្រវេសន៍រួចហើយ
អ្នកបើកបរយកលិខិតឆ្លងដែន របស់ខ្ញុំ។ ខ្ញុំមិនអាចចាកចេញបានទេ
ពីព្រោះលិខិតឆ្លងដែនខ្ញុំនៅជាមួយនិយោជក
ហើយខ្ញុំមិនអាចទៅណាដោយគ្មានលិខិតឆ្លងដែនឡើយ" ។

បុរសជាតិនេប៉ាល់ម្នាក់ធ្វើការជាអ្នកបោសសំអាតនៅប្រទេសអារ៉ាប់រួម

---

និយោជកដែលរក្សាទុកឯកសារអត្តសញ្ញាណ ឬកម្មសិទ្ធិផ្ទាល់ខ្លួនមានតម្លៃឯទៀត គឺជាធាតុផ្សំមួយនៃពលកម្មដោយបង្ខំ ប្រសិនបើពលករមិនអាចយករវត្ថុទាំងនេះវិញនៅពេលត្រូវការ និងប្រសិនបើពួកគេយល់ថា ពួកគេមិនអាចចាកចេញពីការងារដោយពុំមានការបាត់បង់។ ក្នុងករណីជាច្រើន ដោយពុំមានឯកសារអត្តសញ្ញាណពលករនឹងមិនអាចរកការងារឯទៀត ឬមិនអាចទទួលបានសេវាសំខាន់ៗបានទេ ហើយពួកគេអាចមានការភ័យខ្លាចក្នុងការស្នើ សុំជំនួយពីអាជ្ញាធរ ឬអង្គការ NGOs ។



# ការកាត់ប្រាក់ឈ្នួលទុក

"នៅពេលចាប់ផ្តើម គាត់បានសន្យាឱ្យប្រាក់ខែខ្ញុំ ហើយខ្ញុំបានចាប់ផ្តើមធ្វើការ។ គាត់បាន ឱ្យអាហារខ្ញុំ និងជូនកាលគាត់ទិញសំលៀកបំពាក់ឱ្យខ្ញុំ។ ប៉ុន្តែខ្ញុំនៅតែរង់ចាំប្រាក់ខែរបស់ខ្ញុំ។ នៅពេលខ្ញុំសួរគាត់អំពីប្រាក់ខែ គាត់និយាយថា: "ចាំលក់ផលិតផលនេះអស់សិន" ។ ខ្ញុំនៅតែ បន្តធ្វើការជាមួយគាត់។ នៅយប់មួយ ខ្ញុំបានប្រាប់គាត់ថាខ្ញុំចង់ឱ្យគាត់បើកប្រាក់ជំពាក់ឱ្យខ្ញុំ ពីព្រោះខ្ញុំចង់ចាកចេញ។ គាត់ស្ទុះមករកខ្ញុំ ហើយចាប់ផ្តើមវាយតប់ខ្ញុំដោយស្រែកដាក់ខ្ញុំថា "ឯងអាចចាកចេញតាមចិត្តចង់ ប៉ុន្តែខ្ញុំមិនឱ្យអីដល់ឯងទេ " ។ ខ្ញុំយំ ខ្ញុំបានស្នាក់នៅកន្លែង គាត់១៦ខែដោយគ្មានបានអ្វីឡើយ " ។

កុមារអាយុ១៦ឆ្នាំម្នាក់នៅប្រទេសនីហ្សេរីយ៉ា

---

ពលករអាចត្រូវបានគេគំរូវឱ្យរស់នៅជាមួយនិយោជកដែលរំលោភបំពានម្នាក់ខណៈពេលដែលរង់ចាំបើកប្រាក់ខែ។ កត្តានៃការបើកប្រាក់ខែមិនទៀងទាត់ ឬពន្យាការបើកប្រាក់ខែ មិនមានន័យថា ជាស្ថានភាពពលកម្មដោយបង្ខំទេ។ ប៉ុន្តែនៅពេលប្រាក់ខែ ត្រូវបានបង្អកទុក ជាប្រព័ន្ធ ដើម្បីប្រើជាមធ្យោបាយដើម្បីបង្ខំឱ្យពលករស្នាក់នៅបន្ត ហើយបដិសេធមិនឱ្យគាត់ មានពេលដើម្បីប្តូរនិយោជក ចំណុចនេះជាពលកម្មដោយបង្ខំ។



# បំណុលទាសភាព

" ពលករម្នាក់បានខ្ចីប្រាក់ចំនួន២០០០០រូពីពីឈ្មួញកណ្តាលម្នាក់។
នៅពេលគាត់បានសងប្រាក់វិញ ទាំងអស់ ប៉ុន្តែ៥០០០រូពី
ឈ្មួញកណ្តាលនោះបានក្លែងបន្លំដោយទាមទារថា ពលករជំពាក់គាត់
៥០០០០រូពី។ ពលករនោះត្រូវបានបង្ខំឱ្យធ្វើការងារក្នុងការដ្ឋានរករ៉ែ
ដោយកូនប្រុសឈ្មួញកណ្តាលឃ្លាំមើលពីខាងក្រៅ " ។

មេដឹកនាំពលកម្មម្នាក់ក្នុងការដ្ឋានរករ៉ែនៅប្រទេសប៉ាគីស្ថាន

---

ជារឿយៗជនរងគ្រោះដោយពលកម្មដោយបង្ខំធ្វើការងារដើម្បីទូទាត់បំណុលដែលខ្លួនខ្ចី ឬជួន កាលបំណុលពីឪពុកម្តាយ។
បំណុលអាចកើតឡើងពីការបើកប្រាក់ឈ្នួលជាមុន ឬប្រាក់កម្ចីដើម្បីទូទាត់
ការចំណាយលើការជ្រើសរើស ឬការចំណាយដឹកជញ្ជូន ឬពីការចំណាយប្រចាំថ្ងៃ
ឬការចំណាយ ពេលមានអាសន្ន ដូចជាការចំណាយលើថ្លៃព្យាបាល។
បំណុលអាចជាបន្ទុកធ្ងន់ថែមទៀត ជាលទ្ធផល ដោយការបោកបន្លំគណនី
ជាពិសេសនៅពេលពលករជាអនក្ខរជន។ បំណុលទាសភាព ក៏អាចកើត
ឡើងផងដែរ
នៅពេលដែលកុមារត្រូវបានគេជ្រើសរើសដើម្បីជាការដោះដូរសំរាប់ប្រាក់កម្ចី
ដែល ផ្តល់ឱ្យ ឪពុកម្តាយ ឬញាត្តិមិត្តរបស់ពួកគេ។ និយោជក
ឬអ្នកជ្រើសរើសធ្វើបញ្ហានេះឱ្យកាន់តែពិបាក
ដើម្បីកុំឱ្យពលករដកខ្លួនរួចពីបំណុល ដោយផ្តល់តម្លៃការងារយ៉ាងទាប
ឬបង្កើនអត្រាការប្រាក់ ឬបង្កើនការគិតថ្លៃអាហារ និងផ្ទះសំបែង។

បំណុលទាសភាព
ឬការធ្វើការងារដើម្បីដោះបំណុលឆ្លុះបញ្ចាំងពីអតុល្យភាពអំណាចរវាង ពលករ
និងម្ចាស់បំណុល ហើយនិងនិយោជក នឹងកូនបំណុល។
វាមានផលប៉ះពាល់ក្នុងការចងឱ្យ ពលករភ្ជាប់
នឹងនិយោជកក្នុងរយៈពេលគ្មានកំណត់
ការងារអ្វីមួយដែលចេញពីរដូវតែមួយរហូត ដល់ច្រើនឆ្នាំ ឬច្រើនជំនាន់។
វាមិនមានភាពដូចគ្នានឹងប្រាក់កម្ចី "ធម្មតា " ពីធនាគារមួយ ឬពីអ្នក
រកស៊ីចងការប្រាក់ឯទៀត ដែលការទូទាត់សំណងអាស្រ័យលើការព្រមព្រៀងគ្នា
និងរយៈពេល ដែលទទួលយកបាន។



# លក្ខខណ្ឌការងារនិងរស់នៅប្រកបដោយការរំលោភបំពាន

" ពលកររត្រូវបានគេដាក់ឱ្យនៅក្នុងខ្ទមធ្វើពីផ្លាសស្ទីក ផឹកទឹកកខ្វក់ ហើយត្រូវបានគេ ទុកក្នុងរូង ក្រោយគម្ពោតព្រៃ ដើម្បីលាក់ខ្លួនរហូតទាល់តែពួកយើងបានចាកចេញ "។

អ្នកធ្វើអធិការកិច្ចការងារម្នាក់ពិពណ៌នាអំពីលក្ខខណ្ឌនៅប្រេស៊ីល

---

ជនរងគ្រោះដោយពលកម្មដោយបង្ខំទំនងជាត្រូវអត់ធ្មត់នឹងលក្ខខណ្ឌការងារ និងរស់នៅ ដែលពលករមិនដែលទទួលយក។ ពួកគេអាចធ្វើការងារនៅក្រោមលក្ខខណ្ឌដែលធ្វើឱ្យទាប ថោក (កខ្វក់ ឬធ្វើឱ្យអាម៉ាស់) ឬប្រកបដោយគ្រោះថ្នាក់ (ការងារពិបាក ឬគ្រោះថ្នាក់ដោយ គ្មានសំភារៈការពារគ្រប់គ្រាន់) ហើយក្នុងការរំលោភបំពានច្បាប់ការងារយ៉ាងធ្ងន់ធ្ងរ។ ជនរងគ្រោះពលកម្មដោយបង្ខំអាចមាន លក្ខខណ្ឌរស់នៅមិនស្របតាមស្តង់ដារ រស់នៅក្នុងលក្ខខណ្ឌ កុះករជ្រុល និងគ្មានសុខភាព ដោយពុំមានភាពជាឯកជន។

លក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌធ្វើការងារយ៉ាងធ្ងន់ធ្ងរតែមួយមិនអាចបញ្ជាក់តឹកតាង ថាពលកម្មដោយបង្ខំកើតឡើងឡើយ ពីព្រោះថា ជួនកាលមនុស្សខ្លះ "ស្ម័គ្រចិត្ត " ទទួលយក លក្ខខណ្ឌពិបាកៗ ដោយសារកង្វះខាតការងារជាជំរើសផ្សេងណាមួយ។ ទោះជាយ៉ាងណាក្តី លក្ខខណ្ឌដោយរំលោភបំពាននឹងតំណាងជា "ការពញ្ញាក់ " មួយចំពោះការកើតឡើងនៃ ការបង្ខិតបង្ខំជាយថាហេតុដែលរារាំងពលករដែលទទួលរងការកេងប្រវ័ញ្ចមិនឱ្យចាកចេញ ពីការងារ។



# ការធ្វើការបន្ថែមម៉ោងហួសកំណត់

“ខ្ញុំត្រូវធ្វើការ១៩ម៉ោងក្នុងមួយថ្ងៃដោយពុំមានពេលឈប់សំរាក ថ្ងៃឈប់សំរាក ឬការបង់ប្រាក់ថ្លៃធ្វើការបន្ថែមម៉ោងឡើយ។ ពួកគេចាត់ទុកខ្ញុំដូចជាសត្វ ”។

ពលករទេសន្តរប្រវេសន៍ជាតិនេប៉ាល់ម្នាក់

---

ជនរងគ្រោះដោយពលកម្មដោយបង្ខំអាចត្រូវបានគេតំរូវឱ្យធ្វើការហួសម៉ោង ឬហួស ថ្ងៃកំណត់ដែលមានចែងក្នុងច្បាប់ជាតិ ឬកិច្ចព្រមព្រៀងសមូហភាព។ ជនទាំងនោះមិនត្រូវបានគេអនុញ្ញាត្តិឱ្យមានពេលសំរាក ឬថ្ងៃឈប់ទេ ដោយត្រូវទទួលវេន និងម៉ោងធ្វើការរបស់ សហការីណាដែលអវត្តមាន ឬពួកគេត្រូវប្រចាំការ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍។

ការកំណត់ថា តើការធ្វើការបន្ថែមម៉ោង បង្កើតជាបទល្មើសពលកម្មដោយបង្ខំឬអត់ វាពិតជាស្មុគ្រស្មាញណាស់។ តាមបទពិសោធន៍ ប្រសិនបើកម្មករម្នាក់ត្រូវធ្វើការបន្ថែមម៉ោង ច្រើនជាងចំនួនដែលអនុញ្ញាត្តិក្រោមច្បាប់ជាតិ ធ្វើការក្រោមទម្រង់នៃការគំរាមកំហែង (ឧទាហរណ៍ការបណ្តេញចេញ) ឬដើម្បីបើកប្រាក់ឈ្នួលអប្បបរិមាទាំងនេះ ជាពលកម្ម ដោយបង្ខំ។

**កម្មវិធីសកម្មភាពពិសេសដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មដោយបង្ខំ**
**(SAP-FL)**

ការិយាល័យអន្តរជាតិខាងការងារ
Route des Morillons 4
CH-1211 Geneva 22
Forcedlabour@ilo.org
www.ilo.org/forcedlabour